# 44 페인트 작업을 했거든요

## ខ្ញុំបានលាបពណ៌ជញ្ជាំងរួចរាល់ហើយ

**학습 안내**
ការណែនាំអំពីមេរៀន

| | |
|---|---|
| □ វត្ថុបំណងមេរៀន | ការពន្យល់អធិប្បាយពីបរិយាកាសនៅការដ្ឋានធ្វើការ, ការនិយាយពីការរៀបចំទុកដាក់ |
| □ វេយ្យាករណ៍ | –거든요, –아지다/어지다 |
| □ ពាក្យថ្មី | បរិយាកាសនៅការដ្ឋានធ្វើការ, កាកសំណល់រឹងនិងឧបករណ៍សម្អាតកាកសំណល់ |
| □ ព័ត៌មាន · វប្បធម៌ | ការរៀបចំទុកដាក់ឧបករណ៍ធ្វើការងារ |

## 대화 1 ការសន្ទនា ១

Track 136



សូមសាកល្បងស្ដាប់មើលថា តើធូអាន និង រីហាន់កំពុងតែនិយាយគ្នាពីអ្វី? សូមស្ដាប់ ២ដង បន្ទាប់មកសូមថាតាម។

**투안** 어, 리한 씨, 무슨 냄새 나지 않아요? 작업장도 아주 엉망이고요.
អ, រីហាន់, អត់មានធុំក្លិនអីទេហ្អ? ការដ្ឋានធ្វើការក៏រញ៉េរញ៉ៃខ្លាំង។

**리 한** 어제 늦게까지 페인트 작업을 했거든요. 너무 늦어서 정리를 하나도 못하고 퇴근했어요.
ពីព្រោះតែកាលពីម្សិលមិញខ្ញុំបានលាបពណ៌ជញ្ជាំងរហូតដល់យប់ជ្រៅ។ ដោយសារតែធ្វើរហូតដល់ជ្រុលម៉ោងខ្លាំងពេក ដូចនេះទើបខ្ញុំមិនបានសម្អាតសូម្បីតែបន្តិច ហើយក៏ចេញពីធ្វើការទៅ។

**투안** 일 시작하기 전에 환풍기 돌려서 환기부터 해야겠어요. 리한 씨는 작업 도구 먼저 정리해 주세요. 작업 도구는 쓰고 나서 바로바로 정리해야 해요. 안 그러면 나중에 못 쓸 수도 있거든요.
មុនពេលចាប់ផ្ដើមការងារ ត្រូវបើកកង្ហារខ្យល់ ដើម្បីអោយសម្អាតនិងបក់ខ្យល់អាកាសមិនល្អចេញ។ រីហាន់ សូមជួយរៀបចំឧបករណ៍ការងាររបស់អ្នកជាមុនសិន។ ឧបករណ៍ការងារគួរតែត្រូវរៀបចំទុកដាក់សម្អាតភ្លាមៗបន្ទាប់ពីប្រើប្រាស់រួច។ បើមិនដូច្នោះទេ អ្នកនឹងមិនអាចប្រើប្រាស់វាបានទេនៅពេលក្រោយ។

**리 한** 네, 제가 얼른 치울게요. បាទ, ខ្ញុំនឹងប្រញាប់រៀបចំវា។

> **하나도** សូម្បីតែមួយ, សូម្បីតែបន្តិច
> ត្រូវបានប្រើជាមួយពាក្យបដិសេធ ដែលមានន័យថាមិនដែលទាល់តែសោះ, សូម្បីតែបន្តិច។
> · 점심을 못 먹었는데 배가 하나도 안 고파요.
> ខ្ញុំមិនបានញ៉ាំអាហារថ្ងៃត្រង់ទេ ប៉ុន្តែអត់ឃ្លានសូម្បីតែបន្តិច។
> · 한국어는 조금 할 수 있지만 일본어는 하나도 못해요.
> ខ្ញុំអាចនិយាយភាសាកូរ៉េបានតិចតួច ប៉ុន្តែភាសាជប៉ុនវិញ សូម្បីតែបន្តិចក៏អត់ចេះដែរ។

> **바로바로** ភ្លាមៗ
> · 할 일이 있으면 바로바로 하는 것이 좋다.
> ប្រសិនបើមានការងារដែលត្រូវធ្វើ គួរតែធ្វើវាភ្លាមៗទើបជាការល្អ។
> · 무슨 일이 있으면 바로 바로 알려 주세요.
> នៅពេលមានការងារអ្វីមួយដែលត្រូវធ្វើ សូមប្រាប់ខ្ញុំអោយបានដឹងភ្លាមៗផង។



តើអ្នកបានស្ដាប់និងថាតាមការសន្ទនារួចហើយមែនដែរឬទេ? អញ្ចឹងសូមឆ្លើយនឹងសំណួរខាងក្រោម។

1. 작업장에 나는 냄새는 무슨 냄새예요? តើនៅការដ្ឋានមានធុំក្លិនអ្វី?
2. 리한 씨는 먼저 무슨 일을 할 거예요? តើរីហាន់នឹងធ្វើការងារអ្វីមុនគេ?

**정답** 1. 페인트 냄새예요. 2. 작업 도구를 정리할 거예요.

## 어휘 1 ពាក្យថ្មី ១ | 작업장 환경 បរិយាកាសនៅការដ្ឋានធ្វើការ

យើងមកស្វែងយល់អំពីពាក្យដែលជាប់ទាក់ទងទៅនឹងបរិយាកាសនៅការដ្ឋានធ្វើការទាំងអស់គ្នា។



더럽다
កខ្វក់



깨끗하다
ស្អាត



엉망이다
រញ៉េរញ៉ៃ



정리가 잘 되어 있다
រៀបចំបានល្អ



냄새가 심하다
ធុំក្លិនខ្លាំង



소음이 심하다
មានសម្លេងរំខានខ្លាំង



쾌적하다
មានផាសុកភាព



버리다
បោះចោល



치우다
សម្អាត



정리하다
រៀបចំ



환기하다
ផ្លាស់ប្តូរខ្យល់ចេញចូល

សូមកុំមើលពាក្យនៅខាងលើ ហើយសាកល្បងឆ្លើយសំណួរ។

1. 빈칸에 맞는 표현을 〈보기〉에서 골라 문장을 완성하세요.
សូមជ្រើសរើសយកកន្សោមពាក្យពី<ឧទាហរណ៍>មកបញ្ចប់ប្រយោគ។




**보기**
치우다
환기하다
버리다
정리하다

1) 쓰레기를 ____________________.

2) 페인트 통을 ____________________.

3) 작업 도구를 ____________________.

4) 창문을 열고 ____________________.

정답 1) 버려요 2) 치워요 3) 정리해요 4) 환기해요

## 문법 1 វេយ្យាករណ៍ ១ | -거든요

G44-1

យើងប្រើប្រាស់វេយ្យាករណ៍‘-거든요’ភ្ជាប់ជាមួយកិរិយាស័ព្ទនិងគុណនាម ឬភ្ជាប់ជាមួយនាម ដែលមានទម្រង់‘នាម+이다’។ ដើម្បីបង្ហាញអំពីមូលហេតុឬហេតុផលនៃល្បះនៅខាងមុខវា។

| 동사(កិរិយាស័ព្ទ), 형용사(គុណនាម) → **-거든요** |
| --- |
| 울다 → 울**거든요**<br>좋다 → 좋**거든요** |

| 명사(នាម) → **이거든요** | |
| --- | --- |
| 자음(ព្យញ្ជនៈ) → **이거든요** | 모음(ស្រៈ) → **(이)거든요** |
| 학생 → 학생**이거든요** | 휴가 → 휴가**(이)거든요** |

- 가: 작업장이 정말 깨끗하네요. ការដ្ឋានធ្វើការ ពិតជាស្អាត(មានរបៀប/មានសណ្តាប់ធ្នាប់)មែន។
  나: 오전에 청소를 **했거든요**. ដោយសារតែខ្ញុំបានបោសសម្អាតវាកាលពីពេលព្រឹកមិញ។
- 가: 내일부터 일주일 동안 쉬어요? ចាប់ពីថ្ងៃស្អែកទៅ តើអ្នកឈប់សម្រាករយៈពេល១សប្តាហ៍ឬ?
  나: 네, **여름 휴가거든요**. បាទ, ពីព្រោះជាថ្ងៃឈប់សម្រាករដូវក្តៅ។



តើអ្នកបានយល់ពីការប្រើប្រាស់វេយ្យាករណ៍‘-거든요’ហើយមែនដែរឬទេ? អញ្ចឹងសូមសាកល្បងសរសេរ កន្សោមពាក្យដែលត្រឹមត្រូវទៅនឹងចន្លោះមកបញ្ចប់ការសន្ទនាខាងក្រោម។

2. 그림을 보고 ‘-거든요’를 사용해서 대화를 완성하세요.
សូមមើលរូបភាព បន្ទាប់មកចូរប្រើវេយ្យាករណ៍‘-거든요’មកបញ្ចប់ការសន្ទនា។

1) 

가: 작업장이 아주 깨끗하네요.
ការដ្ឋានធ្វើការ ពិតជាស្អាត(មានរបៀប/មានសណ្តាប់ធ្នាប់)មែន។
나: 그렇죠? 어제 ______________________.
ត្រូវតែអញ្ចឹងហើយ។ ពីព្រោះខ្ញុំបានបោសសម្អាតវាកាលពីម្សិលមិញ។

2) 

가: 밖이 왜 이렇게 시끄러워요? នៅខាងក្រៅហេតុអ្វីបានជាមានសម្លេងថ្លង់ម្លេះ?
나: 지금 ______________________.
ពីព្រោះឥឡូវនេះ មានសំណង់កំពុងតែសាងសង់។

정답 1) 청소했거든요 2) 공사를 하고 있거든요



យើងរៀនថែមបន្តិចទៀតតើល្អដែរឬទេ? សូមប្រើវេយ្យាករណ៍‘-거든요’ ទៅបំពេញប្រយោគខាងក្រោម។

1) 시장에서 장을 봤어요. 시장이 물건 값이 ______________________.
ខ្ញុំបានទិញម្ហូបអាហារនៅឯផ្សារ។ ពីព្រោះតម្លៃទំនិញនៅផ្សារមានតម្លៃថោក។

2) 오늘은 야근을 해야 돼요. 일이 ______________________.
ថ្ងៃនេះ ខ្ញុំត្រូវតែធ្វើការបន្ថែមពេលយប់។ ពីព្រោះមានការងារច្រើន។

정답 1) 싸거든요 2) 많거든요

## 대화 2 ការសន្ទនា ២

Track 137



ហៀអង់និងស៊ូភីខាកំពុងតែនិយាយជាមួយនិងមីងម្ចាស់កសិដ្ឋាន។
ដំបូងសូមស្ដាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន រួចហើយចូរថាតាម។

**주인 아주머니** 매일 치워도 이렇게 분뇨가 쌓이니까 치우기 너무 힘들지요?
សម្អាតរាល់ថ្ងៃហើយនៅតែមានលាមកសត្វគរអញ្ចឹងទៀត ដូចនេះវាពិបាកក្នុងការសម្អាតខ្លាំងហើយមែនអត់?

**흐엉** 좀 힘들기는 한데요. 그래도 하루라도 안 치우면 너무 지저분해지잖아요.
វាពិបាកសម្អាតពិតមែន។ តែបើសិនជាមិនបានសម្អាតវាតែមួយថ្ងៃ នោះវានឹងកខ្វក់ពាសពេញកន្លែងហ្នឹងជាមិនខាន។

**수피카** 맞아요. 그런데 사모님, 어제 보니까 분뇨 버리는 곳에 다른 쓰레기도 많던데 따로 분리해서 버려야 하는 거 아니에요?
ពិតមែនហើយ។ ប៉ុន្តែលោកស្រី, កាលពីម្សិលមិញតាមដែលខ្ញុំមើលទៅកន្លែងចោលលាមកសត្វឃើញមានសំរាមផ្សេងៗដទៃទៀតជាច្រើន។ ប៉ុន្តែយើងត្រូវតែបែងចែកសំរាមដោយឡែកៗពីគ្នា រួចហើយសឹមបោះចោលមិនអញ្ចឹងឬ?

**주인 아주머니** 안 그래도 사장님이 폐기물 처리하는 것 때문에 시청에 가셨어요. 처리 방법이 좀 까다로워져서 교육 받고 오시면 말씀하실 거예요.
ទោះបីជាមិនអញ្ចឹងក៏ដោយលោកថៅកែបានទៅសាលាក្រុង ដោយសារតែការចោលកាកសំណល់នេះ។ វិធីសាស្រ្តក្នុងការចោលកាកសំណល់កាន់តែល្អិតល្អន់ទៅហើយ ដូច្នេះពេលលោកថៅកែគាត់ត្រឡប់មកពីទទួលការអប់រំបណ្ដុះបណ្ដាលវិញ គាត់នឹងប្រាប់ដល់អ្នកទាំងអស់គ្នា។

**그래도** ទោះជាយ៉ាងនេះក៏ដោយ

- 일이 많아서 힘들어요. 그래도 행복해요.
  វាពិបាកដោយសារតែមានការងារច្រើន។ ទោះជាយ៉ាងនេះក៏ដោយក៏ខ្ញុំសប្បាយចិត្តនឹងការងារដែរ។
- 아침부터 머리가 많이 아팠어요. 그래도 일하러 나왔어요.
  ខ្ញុំឈឺក្បាលខ្លាំងណាស់តាំងពីព្រឹកមកម្លេះ។ ទោះជាយ៉ាងនេះក៏ដោយក៏ខ្ញុំចេញមកធ្វើការងារដែរ។

**안 그래도** ទោះបីជាមិនអញ្ចឹងក៏ដោយ

- 먼저 전화하셨네요. 안 그래도 전화드리려고 했습니다.
  អរគុណហើយដែលបានទូរស័ព្ទមករកខ្ញុំមុន។ ទោះបីជាមិនអញ្ចឹងក៏ដោយក៏ខ្ញុំមានបំណងចង់ទូស័ព្ទទៅអ្នកស្រាប់ផង។
- 가: 내일 백화점에 같이 갈래요?
  ថ្ងៃស្អែកទៅផ្សារទំនើបជាមួយគ្នាទេ?
  
  나: 안 그래도 가려고 했었는데 잘됐네요.
  ល្អហើយអញ្ចឹង, ទោះបីជាមិនអញ្ចឹងក៏ដោយ ក៏ខ្ញុំកំពុងមានបំណងចង់ទៅស្រាប់ផង ។



តើអ្នកបានស្ដាប់ និង ថាតាមហើយឬនៅ? អញ្ចឹង សូមឆ្លើយសំណួរខាងក្រោម។

1. 사장님은 지금 어디에 가셨어요? តើលោកថៅកែ បានអញ្ជើញទៅណា?
2. 분뇨는 얼마나 자주 치워요? តើការសម្អាតលាមកសត្វញឹកញាប់ប៉ុណ្ណាដែរ?

**정답** 1. 시청에 가셨어요. 2. 분뇨는 매일 치워요.

**វាក្យស័ព្ទថ្មី**

처리하다 ចាត់ចែង　분리하다 បែងចែក　까다롭다 សំរិតសំរាំង

## 어휘 2 ពាក្យថ្មី ២ | 폐기물과 정리 도구 កាកសំណល់រឹង និង ឧបករណ៍សម្អាតកាកសំណល់



តោះយើងស្វែងយល់ពីពាក្យដែលជាប់ទាក់ទងនឹងកាកសំណល់និងការរៀបចំសម្អាតឧបករណ៍ប្រើប្រាស់ទាំងអស់គ្នា។



폐기물
កាកសំណល់រឹង



폐수
កាកសំណល់ទឹក(រាវ)



폐유
កាកសំណល់ប្រេង



분뇨/배설물
លាមក



환풍기
កង្ហារខ្យល់(ម៉ាស៊ីនសម្អាតខ្យល់)



손수레
រទេះរុញ(ដោយប្រើដៃ)



일륜차
រទេះរុញ



사다리
ជណ្ដើរ(មានជើង)



마대
បាវ



바구니
កន្ត្រក



비닐 끈
ខ្សែប្លាស្ទិច



សូមកុំមើលពាក្យដែលនៅខាងលើ ហើយសាកល្បងឆ្លើយសំណួរខាងក្រោម។

1. 그림을 보고 알맞은 말을 연결하세요. សូមពិនិត្យមើលរូបភាព ហើយផ្គូរផ្គងជាមួយនឹងពាក្យដែលត្រឹមត្រូវ។

①  ②  ③  ④  ⑤ 

㉠ 분뇨 ㉡ 사다리 ㉢ 폐수 ㉣ 환풍기 ㉤ 비닐 끈

정답 ①㉢ ②㉠ ③㉣ ④㉡ ⑤㉤

## 문법 2 វេយ្យាករណ៍ ២ | –아지다/어지다

G44-2

វេយ្យាករណ៍ '–아지다/어지다' ប្រើភ្ជាប់ជាមួយគុណនាម ដើម្បីបង្ហាញពីការផ្លាស់ប្តូរស្ថានភាពអ្វីមួយ។

| ㅏ, ㅗ → **–아지다** | ㅓ, ㅜ, ㅣ -ㅥ- → **–어지다** | 하다 → **해지다** |
|---|---|---|
| 작다 → 작**아지다**<br>많다 → 많**아지다** | 크다 → **커지다**<br>적다 → 적**어지다** | 조용하다 → 조용**해지다** |

- 매일 아침 운동을 하니까 **건강해졌어요**. ខ្ញុំហាត់ប្រាណរៀងរាល់ព្រឹក ដូចនេះហើយខ្ញុំមានសុខភាពល្អច្រើន។
- 가: 환풍기를 고치니까 어때요? កង្ហារខ្យល់ជួសជុលរួចហើយអញ្ចឹង វាដំណើរការស្រួលហើយ ឬយ៉ាងណាដែរ?
  나: 실내 공기가 훨씬 **깨끗해졌어요**. ខ្យល់នៅក្នុងផ្ទះ/អាគារ វាប្រែជាល្អបរិសុទ្ធច្រើន។

នៅពេលដែល '–아지다/어지다' ប្រើភ្ជាប់ជាមួយនឹង គុណនាម នោះវានឹងប្រែក្លាយទៅជា កិរិយាស័ព្ទ។
ដូចនេះ វាអាចប្រើជាមួយនឹងទំរង់ '–고 있다' ហើយមានន័យថា កំពុងដំណើរការធ្វើអ្វីមួយ។

- 날씨가 점점 덥고 있어요. (X)
  날씨가 점점 **더워지고 있어요**. (O) អាកាសធាតុកំពុងប្រែទៅជាក្តៅទៅៗបន្តិចម្តងៗ។
- 공장이 점점 깨끗하고 있어요. (X)
  공장이 점점 **깨끗해지고 있어요**. (O) រោងចក្រប្រែទៅជាស្អាត មានអនាម័យបន្តិចម្តងៗ។

### 크메르어와 한국어의 공통점과 차이점 ចំណុចដូចគ្នានិងខុសគ្នារវាងភាសាខ្មែរនិងភាសាកូរ៉េ

នៅក្នុងភាសាខ្មែរ នៅពេលដែលមានការប្រែប្រួល ផ្លាស់ប្តូរ សភាពអ្វីមួយ គេប្រើកិរិយាស័ព្ទពាក្យ "ប្រែជា, ក្លាយទៅជា", តែនៅក្នុងភាសាកូរ៉េគេប្រើ វេយ្យាករណ៍ '–아/어지다' ភ្ជាប់ជាមួយនឹងផ្នែកខាងចុងនៃពាក្យគុណនាម។

- 날씨가 (어제보다) 추**워졌어요.** អាកាសធាតុប្រែជាចុះត្រជាក់(ជាងកាលពីម្សិលមិញ)។



តើអ្នកបានយល់ពី វេយ្យាករណ៍ '–아지다/어지다' ហើយឬនៅ? អញ្ចឹងសូមសាកល្បងប្រើកន្សោមពាក្យដែលមាន យកទៅបំពេញប្រយោគខាងក្រោម។

2. '–아지다/어지다'를 사용하여 문장을 완성하세요.
សូមប្រើវេយ្យាករណ៍ '–아지다/어지다' ទៅបំពេញប្រយោគខាងក្រោម។

1) 강물이 깨끗하다 → 강물이 더럽다

폐수 때문에 ________________________________.

2) 동네가 조용하다 → 동네에 소음이 심하다

공사를 해서 ________________________________.

3) 작업 환경이 나쁘다 → 작업 환경이 쾌적하다

정리 정돈을 잘 하니까 ________________________________.

정답 1) 강물이 더러워졌어요 2) 동네에 소음이 심해졌어요 3) 작업 환경이 쾌적해졌어요

## 활동 សកម្មភាព

다음을 읽고 질문에 답하세요. សូមអាន រួចឆ្លើយនឹងសំណួរខាងក្រោម។

### 정리 정돈은 왜 해야 할까요?
ហេតុអ្វីបានជាយើងត្រូវរៀបចំទុកដាក់?





1. 물건과 장소의 낭비를 줄일 수 있습니다.
   អាចជួយកាត់បន្ថយការខ្ជះខ្ជាយវត្ថុប្រើប្រាស់ និងទីកន្លែងបាន។
2. 안전사고를 예방할 수 있습니다. អាចជួយការពារពីគ្រោះថ្នាក់បាន។
3. 기계를 오랫동안 잘 사용할 수 있습니다. អាចធ្វើឲ្យម៉ាស៊ីនប្រើបានយូរ។
4. 제품의 품질이 좋아집니다. ធ្វើឲ្យគុណភាពនៃផលិតផលកាន់តែល្អប្រសើរ។
5. 생산 품종이 변경될 때 손실을 줄일 수 있습니다.
   អាចជួយកាត់បន្ថយការបាត់បង់ ការខូចខាត នៅពេលដែលពូជផលិតកម្មត្រូវបានផ្លាស់ប្តូរ។
6. 즐거운 직장, 발전하는 회사가 될 수 있습니다.
   អាចជាកន្លែងធ្វើការប្រកបដោយភាពរីករាយ, អាចក្លាយទៅជាក្រុមហ៊ុនដែលមានការអភិវឌ្ឍន៍។

1. 읽은 내용과 같으면 ○, 다르면 X에 표시하세요.
   សូមគូស ○ ចំពោះចម្លើយដែលមានខ្លឹមសារដូចទៅអត្ថបទដែលអ្នកបានអាន, ហើយគូស X ចំពោះចម្លើយដែល ខុស។

   1) 정리를 잘하면 안전사고를 줄일 수 있습니다. ○ X

   2) 정리를 잘하면 기계를 빨리 바꿀 수 있습니다. ○ X

   3) 정리를 잘하면 회사에서 더 즐겁게 일할 수 있습니다. ○ X

정답 1. 1) O 2) X 3) O

## 정보 ព័ត៌មាន

# 작업 도구 정리 정돈
ការរៀបចំទុកដាក់ឧបករណ៍ធ្វើការងារ



### 사용 목적에 따른 공구 정리
រៀបចំឧបករណ៍ទៅតាមគោលបំណងនៃការប្រើប្រាស់

공구는 많은 종류가 있지만 본래의 목적 이외에 사용하는 것은 위험합니다. 알맞은 종류와 크기의 공구를 사용하기 쉬운 곳에 준비해 두세요.

មានឧបករណ៍ជាច្រើនប្រភេទ ប៉ុន្តែការប្រើប្រាស់វាហួសពីគោលបំណងដើមគឺមានគ្រោះថ្នាក់ណាស់។ សូមរៀបចំទុកដាក់រក្សាឧបករណ៍ទៅតាមប្រភេទនិងទំហំអោយបានត្រឹមត្រូវទៅតាមកន្លែងដើម នោះវានឹងធ្វើឲ្យងាយស្រួលក្នុងការយកមកប្រើប្រាស់។

### 공구 점검 ការត្រួតពិនិត្យឧបករណ៍

공구는 항상 점검을 해야 합니다. 고장이 난 것은 폐기하거나 수리해서 사용해야 합니다.

ឧបករណ៍ប្រើប្រាស់ គួរតែត្រូវបានត្រួតពិនិត្យជានិច្ច។ ឧបករណ៍ដែលខូច គួរតែបោះចោល ឬ ជួសជុលប្រើប្រាស់ឡើងវិញ។





### 공구 사용 시 주변 정리 정돈
ស្របពេលដែលប្រើឧបករណ៍ គួររៀបចំទុកដាក់សម្អាតជុំវិញកន្លែងនោះ

공구를 사용할 장소는 잘 정리되어 있어야 합니다. 공구에 손이나 발을 다치거나 공구가 떨어져서 다칠 수도 있습니다.

ត្រូវតែរៀបចំកន្លែងដែលប្រើឧបករណ៍ឱ្យបានល្អត្រឹមត្រូវ។ ពីព្រោះឧបករណ៍ទាំងនោះ អាចធ្វើឲ្យមានរបួសដល់ដៃឬជើងរបស់អ្នក ឬក៏ឧបករណ៍នោះអាចធ្លាក់ហើយអាចនឹងធ្វើឱ្យអ្នកមានរបួសដោយប្រការណាមួយបាន។

### 보관 ការរក្សាទុក

공구함을 준비하여 종류와 크기별로 공구를 구별하여 보관해야 합니다. 공구를 안전하고 쉽게 사용할 수 있습니다.

ត្រូវតែរៀបចំប្រអប់សម្រាប់ផ្ទុកឧបករណ៍ ហើយត្រូវតែរៀបចំបែងចែកទៅតាមប្រភេទនិងទំហំ រួចហើយយកទៅទុកដាក់អោយស្រួលបួល។ ពីព្រោះវាធ្វើឲ្យយើងប្រើឧបករណ៍នោះប្រកបដោយមានសុវត្ថិភាពនិងមានភាពងាយស្រួល។



# EPS-TOPIK 듣기 វិញ្ញាសាស្តាប់ EPS-TOPIK



សំណួរទី១ និងទី២ ជាសំណួរដែលតម្រូវឲ្យស្តាប់ការសន្ទនា ហើយជ្រើសរើសចម្លើយដែលមានន័យជាប់ទាក់ទងនឹងការសន្ទនា។ មុននឹងស្តាប់ការសន្ទនា សូមពិនិត្យមើលខ្លឹមសាររបស់ចម្លើយជាមុនសិន។

[1~2] 들은 것을 고르십시오. ចូរជ្រើសរើសចម្លើយដែលអ្នកបានស្តាប់លឺ។ Track 138

1. ① 폐유 ② 폐수
   ③ 폐기 ④ 폐물

2. ① 작업장이 깨끗해요. ② 작업장을 치웠어요.
   ③ 작업장이 더러워요. ④ 작업장을 정리해요.



សំណួរទី៣ និងទី៤ គឺជាសំណួរដែលត្រូវស្តាប់ការសន្ទនា ហើយជ្រើសរើសរូបភាពដែលមានខ្លឹមសារទាក់ទងទៅនឹងការសន្ទនា។ មុននឹងស្តាប់ សូមសាកល្បងពិនិត្យមើលរូបភាពជាមុនសិន។ សំណួរទី៥ជាសំណួរជ្រើសរើសចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ ក្រោយពីស្តាប់ការនិយាយរបស់បុរស។

[3~4] 잘 듣고 내용과 관계있는 그림을 고르십시오.
ចូរស្តាប់ដោយយកចិត្តទុកដាក់ ហើយជ្រើសរើសចម្លើយដែលមានអត្ថន័យទាក់ទងនឹងខ្លឹមសារអត្ថបទ។

3. ①  ②  ③  ③ 

4. ①  ②  ③  ③ 

5. 이야기를 듣고 질문에 알맞은 대답을 고르십시오.
ចូរស្តាប់ការសន្ទនា បន្ទាប់មកជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

남자가 말한 정리 정돈의 효과로 맞지 않는 것을 고르십시오.
ចូរជ្រើសរើសចម្លើយដែលខុសពីអ្វីដែលបុរសម្នាក់នេះបាននិយាយពីអត្ថប្រយោជន៍នៃការរៀបចំទុកដាក់។

① 품질이 떨어질 수 있어요.
② 안전사고를 예방할 수 있어요.
③ 물건의 낭비를 줄일 수 있어요.
④ 기계를 오래 사용할 수 있어요.



### 듣기 대본 អត្ថបទនៅក្នុងវិញ្ញាសាស្តាប់

1. 여: 폐수를 여기에 버리는 거예요? កាកសំណល់រាវ បោះចោលនៅទីនេះមែនទេ?
   남: 네, 여기가 폐수를 버리는 곳이에요. បាទ, ទីនេះ គឺជាកន្លែងសម្រាប់ចោលកាកសំណល់រាវ។
2. 여: 작업장이 더러워요. ការដ្ឋានធ្វើការ កខ្វក់។
   남: 그렇죠? 너무 지저분하네요. មែនហ្នឹង? កខ្វក់រញ៉េរញ៉ៃមែនហ្នឹង។
3. 남: 사다리가 있으면 올라갈 수 있겠네요. បើមានជណ្ដើរជើង អាចឡើងទៅលើបានហើយ។
   여: 사다리요? 저기에 있네요. ជណ្ដើរជើងមែនទេ? វានៅទីនោះ។
4. 남: 지금 뭐 하고 있어요? តើឥឡូវអ្នកកំពុងធ្វើអ្វី?
   여: 냄새가 나서 환기하고 있어요. ដោយសារមានធុំក្លិន ដូចនេះហើយកំពុងតែផ្លាស់ប្តូរខ្យល់ចេញចូល។
5. 남: 오늘 교육 시간에는 지난주에 이어서 작업장 정리가 왜 필요한지 설명하겠습니다. 우선 정리를 잘하면 안전사고를 예방할 수 있고, 물건의 낭비를 줄일 수 있어요. 그리고 제품을 잘 관리하니까 품질도 좋아지고요. 무엇보다 기계를 오랫동안 잘 사용할 수 있어요.
   វគ្គបណ្ដុះបណ្ដាលថ្ងៃនេះ នឹងពន្យល់បង្ហាញពីមូលហេតុ ដែលយើងត្រូវសម្អាតកន្លែងធ្វើការ បន្ទាប់ពីការពន្យល់បង្ហាញពីសប្ដាហ៍មុន។ ដំបូងបង្អស់ គឺប្រសិនបើយើងរៀបចំទុកដាក់ឱ្យបានល្អនោះ យើងអាចការពារពីគ្រោះថ្នាក់និងកាត់បន្ថយការខ្ជះខ្ជាយវត្ថុប្រើប្រាស់បាន។ ហើយក៏ជួយថែរក្សាគ្រប់គ្រងផលិតផលឱ្យបានល្អ ដូចនេះហើយវាជួយពង្រឹងគុណភាពផលិតផលអោយកាន់តែល្អប្រសើរថែមទៀត។ អ្វីដែលល្អបំផុតនោះគឺយើងអាចប្រើម៉ាស៊ីនបានកាន់តែយូរ។

정답 1. ② 2. ③ 3. ③ 4. ① 5. ①

## 확장 연습 លំហាត់អនុវត្តបន្ថែម

L-44

1. 대화를 듣고 질문에 알맞은 것을 고르십시오.
   ចូរស្តាប់ការសន្ទនា ហើយជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

   남자가 사무실에 가는 이유는 무엇입니까? តើមូលហេតុអ្វីបានជាបុរសទៅការិយាល័យ?

   ① 마스크를 잊어버려서 ② 작업장에 먼지가 많아서
   ③ 사무실에서 일해야 해서 ④ 귀마개를 안 가지고 와서

### 확장 연습 듣기 대본 អត្ថបទស្តាប់នៅក្នុងលំហាត់អនុវត្តបន្ថែម

1. 여: 바트 씨, 귀마개하고 마스크 가지고 왔지요?
   បាធឿ, តើលោកបានយកកាសត្រចៀកការពារសុវត្ថិភាព និង ម៉ាស់ការពារផ្ទៃមុខ មកហើយមែនទេ?
   남: 오늘 작업은 먼지가 많이 난다고 해서 마스크만 가지고 왔는데요.
   ដោយសារថ្ងៃនេះមានធូលីច្រើន ដូចនេះហើយខ្ញុំបានយកតែម៉ាសការពារផ្ទៃមុខមកតែប៉ុណ្ណោះ ។
   여: 여기는 소음이 심해서 귀마개를 꼭 착용해야 해요.
   នៅទីនេះ មានសម្លេងរំខានខ្លាំង ដូចនេះហើយអ្នកត្រូវតែពាក់កាសត្រចៀកការពារសុវត្ថិភាពជាដាច់ខាត។
   남: 몰랐어요. 사무실에 가서 얼른 가지고 올게요.
   ខ្ញុំអត់បានដឹងសោះ។ ខ្ញុំនឹងទៅការិយាល័យ ទៅយកកាសត្រចៀកការពារសុវត្ថិភាពឲ្យបានលឿនរួចត្រឡប់មកវិញ។

정답 1. ④

# EPS-TOPIK 읽기 វិញ្ញាសាអាន EPS-TOPIK

សំណួរទី១ និងទី២ គឺជាសំណួរដែលមើលរូបភាព ហើយរកកន្សោមពាក្យដែលត្រឹមត្រូវ។
សូមរំលឹកអំពីអ្វីដែលបានរៀននៅខាងលើ ហើយដោះស្រាយសំណួរខាងក្រោម។

[1~2] 다음 그림을 보고 맞는 문장을 고르십시오. ចូរក្រលេកមើលរូបភាព ហើយជ្រើសរើសប្រយោគដែលត្រឹមត្រូវ។

1. 

① 손수레입니다. ② 배설물입니다.
③ 일륜차입니다. ④ 비닐 끈입니다.

2. 

① 냄새가 심해요. ② 소음이 심해요.
③ 공기가 쾌적해요. ④ 정리가 되어 있어요.

ចាប់សំណួរទី៣ ដល់ ទី៥ គឺជាសំណួរជ្រើសរើសកន្សោមពាក្យដែលត្រឹមត្រូវយកទៅបំពេញចន្លោះ
ខាងក្រោម។ សូមរំលឹកអំពីអ្វីដែលបានរៀនរួចមកហើយនោះបណ្តើរ និងឆ្លើយសំណួរបណ្តើរ។

[3~5] 빈칸에 들어갈 가장 알맞은 것을 고르십시오.
ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវជាងគេមកបំពេញចន្លោះខាងក្រោម។

3.
가: 오늘은 작업장이 아주 쾌적하네요. ថ្ងៃនេះ ការដ្ឋានធ្វើការពិតជាមានផាសុកភាពមែន។
나: 그렇죠? 청소를 ______________. ត្រូវតែអញ្ចឹងហើយ។ ពីព្រោះខ្ញុំបានបោសសម្អាតវា ។

① 하지요 ② 했거든요 ③ 하고 싶어요 ④ 할 거예요

4.
가: 며칠 전보다 분뇨가 ______________. លាមកសត្វមានកាន់តែច្រើនទៅៗ ជាងកាលពីប៉ុន្មានថ្ងៃមុន។
나: 그렇죠? 빨리 치워야겠어요. បែបអញ្ចឹងហើយមើលទៅ? ត្រូវតែសម្អាតវាអោយបានលឿន។

① 많아졌어요 ② 많으면 안 돼요
③ 많지 않을 거예요 ④ 많았으면 좋겠어요

5.
공구함을 준비하여 종류와 크기별로 공구를 구별하여 _________해야 합니다.
ត្រូវតែរៀបចំប្រអប់សម្រាប់ផ្ទុកឧបករណ៍ ហើយត្រូវតែរៀបចំបែងចែកទៅតាមប្រភេទ និងទំហំ រួចហើយយកទៅទុកដាក់អោយស្រួលបួល។

이렇게 잘 넣어 두면 공구를 안전하고 쉽게 사용할 수 있습니다.
រៀបទុកដាក់អោយស្រួលបួលអញ្ចឹង ធ្វើឲ្យយើងមានភាពងាយស្រួល និង ប្រកបដោយសុវត្ថិភាពក្នុងការយកឧបករណ៍មកប្រើប្រាស់ផងដែរ។

① 사용 ② 보관 ③ 준비 ④ 점검

정답 1. ① 2. ② 3. ② 4. ① 5. ②



## 확장 연습 លំហាត់អនុវត្តបន្ថែម

[1~3] 빈칸에 들어갈 가장 알맞은 것을 고르십시오. ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវជាងគេ មកបំពេញចន្លោះខាងក្រោម។

1. 새 작업 도구로 작업을 하니까 아주 편합니다. 전에 쓰던 것보다 ______ 작고 가벼워서 좋습니다.
ប្រើឧបករណ៍ថ្មីធ្វើការងារអញ្ចឹង វាធ្វើឲ្យមានភាពងាយស្រួលច្រើនក្នុងការធ្វើការ។ វាល្អក្នុងការប្រើប្រាស់ ព្រោះវាតូចជាងនិងស្រាលច្រើនជាងឧបករណ៍ប្រើមុនៗ។

① 혹시　② 계속
③ 가장　④ 훨씬

2. 작업장의 기계가 낡아서 새 기계로 바꾸었습니다. 새 기계로 ______ 더 쉽고 편한 것 같습니다.
ម៉ាស៊ីននៅឯការដ្ឋានធ្វើការចាស់ៗ ត្រូវបានជំនួសដោយម៉ាស៊ីនថ្មីៗ។ ដោយសារធ្វើការជាមួយម៉ាស៊ីនថ្មីៗអញ្ចឹង វាហាក់ដូចជាធ្វើឲ្យមានភាពងាយស្រួលនិងមានផាសុកភាពជាងមុន។

① 작업하니까　② 작업하든지
③ 작업하고자　④ 작업하려고

3. 페인트 작업을 한 다음에는 바닥을 잘 닦아야 합니다. 그렇게 하지 않으면 사람들이 다니다가 ______________.
បន្ទាប់ពីលាបពណ៌ជញ្ជាំងរួច ត្រូវតែជូតសម្អាតកំរាលឥដ្ឋឱ្យបានស្អាត។ បើមិនអញ្ចឹងទេ វានឹងធ្វើឲ្យមនុស្សដែលដើរកាត់កន្លែងហ្នឹង អាចរអិលដួលបាន។

① 찔리면 됩니다　② 찔릴 수 있습니다
③ 미끄러지면 됩니다　④ 미끄러질 수 있습니다

정답 1. ④　2. ①　3. ④

## 발음 ការបញ្ចេញសម្លេង

P-22

### សូមស្តាប់ដោយយកចិត្តទុកដាក់រួចថាតាម

ក្នុងភាសាកូរ៉េ កាលណា មានព្យញ្ជនៈ ២ ជួបគ្នា វានឹងកើតមាន ការផ្លាស់ប្តូរផ្នែកសូរស័ព្ទជាច្រើនកើតឡើង។ ក្នុងករណីដែលពពួកព្យញ្ជនៈដែលបញ្ចេញខ្យល់សម្លេងតាមច្រមុះ ដូចជាព្យញ្ជនៈ ‘ㄴ’ ជួបជាមួយនឹង ពពួកព្យញ្ជនៈដែលបញ្ចេញសម្លេងគ្រលាស់តាមនិងដោយប្រើអណ្តាត ដូចជាព្យញ្ជនៈ ‘ㄹ’ ដូចជាក្នុងករណី ‘ㄴ + ㄹ’, ‘ㄹ + ㄴ’ នេះដែរ គឺមិនគិតពីលំដាប់លំដោយនៃតួព្យញ្ជនៈមួយណានៅខាងមុខ ឬ នៅខាងក្រោយនោះទេ កាលណាព្យញ្ជនៈទាំង២ ជួបគ្នាបែបនេះ វាប្រែបញ្ចេញសម្លេងអានទៅជា [ㄹㄹ]វិញ។

(1) 설날, 오늘날, 일 년　(2) 신라, 한라산, 천 리
(3) 컴퓨터는 아주 편리해요.　(4) 설날에는 떡국을 먹어요